# សៀវភៅថ្មីរបស់សហភាពអន្តរសភាស្តីពី វិធីសាស្ត្រកៀរគរសភាក្នុងការជួយ លុបបំបាត់ការរើសអើងចំពោះស្ត្រី




Inter-Parliamentary Union For democracy. For everyone. 1889

ថ្ងៃអាទិត្យ ១៥កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៣

កាលពី២០ឆ្នាំមុន សហភាពអន្តរសភា(IPU) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) បានចេញផ្សាយសៀវភៅមួយសម្រាប់សមាជិកសភា ស្តីពីអនុញ្ញាលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រី និងពិធីសារជាជម្រើស(Handbook for Parliamentarians on Convention on the Eliminiation of All Fomrs of Discriminiation against Women and its Optional Protocols)។ នៅពេលនេះ ស្ថាប័នទាំងពីរបានធ្វើបច្ចុប្បន្នភាពសៀវភៅនេះ និងចេញផ្សាយលើកទី២។

## តើអ្វីជាអនុសញ្ញាCEDAW(ស៊ីដ)?

អនុសញ្ញាCEDEW គឺជាអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រី។ ទោះបីជាអនុសញ្ញានេះត្រូវបានអនុម័តកាលពីជាង៤ទសវត្សរ៍មុនក៏ដោយ ក៏បច្ចុប្បន្ននេះ អនុសញ្ញានេះ នៅតែឧបករណ៍ដ៏សំខាន់សម្រាប់ការសម្រេចបាននូវសមភាពយេនឌ័រ និងការការពារសិទ្ធិស្ត្រីនៅគ្រប់ស្រទាប់វណ្ណៈ-- តាំងពីស្ត្រីបម្រើការងារក្រុមគ្រួសារ ក្នុងថ្នាក់រៀន រហូតដល់ស្ត្រីបម្រើការក្នុងក្រុមប្រឹក្សាប្រតិបត្តិ និងក្នុងស្រទាប់ថ្នាក់ដឹកនាំនយោបាយ។ សៀវភៅថ្មីនេះ ជួយសមាជិកសភាក្នុងការប្រើក្លាយអនុសញ្ញាខាងលើ ទៅជាសកម្មភាពដ៏រឹងមាំរបស់សភា តាមរយៈមុខងារនីតិកម្ម មុខងារបែងចែកថវិកា និងមុខងារត្រួតពិនិត្យសកម្មភាពរដ្ឋាភិបាល។ សៀវភៅថ្មីនេះ ក៏ជាគ្រឿងលើកទឹកចិត្តមួយទៀតដែរ ដល់សមាជិកសភាក្នុងការនាំមុខគេ នៅពេលធ្វើការងារពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិស្ត្រី។

## ការរើសអើងចំពោះស្ត្រី

ការរើសអើងចំពោះស្ត្រី ជាទង្វើដែលលម្អៀងផ្នែកយេនឌ័រ ហើយទង្វើនេះកំពុងកើតឡើងទូទាំងពិភពលោក។ ទិន្នន័យរបស់សហភាពអន្តសភា នៅពេលនេះ បានបង្ហាញថាសមាមាត្រស្ត្រីក្នុងសភា បាននៅទ្រឹងត្រឹមចំនួនប្រហែល២៦% ទោះបីជាប៉ុន្មានឆ្នាំមុននេះមានការកើនឡើងក្នុងនិន្នាការថេរក៏ដោយ។ យោងតាមទិន្នន័យរបស់ធនាគារពិភពលោក(The World Bank) ស្ត្រីនិងកុមារីទទួលបានសិទ្ធិស្របច្បាប់តែ៧៧% ប៉ុណ្ណោះនៃធៀបនឹងសិទ្ធិស្របច្បាប់ដែលបុរស និងកុមារាទទួលបាន។ ចំណែកទិន្នន័យរបស់វេទិកាសេដ្ឋកិច្ចពិភពលោកវិញ ទិន្នន័យនេះបានគណនាឃើញថា ស្ត្រីនៅទូទាំងពិភពលោក រកប្រាក់ចំណូលបាន៣៧%តិចជាបុរស ដែលមានការងារនិងតួនាទីដូចគ្នា ហើយវឌ្ឍនភាពនៃការបន្ថយគម្លាតប្រាក់ខែរវាងបុរស-ស្ត្រី(ដែលមានតួនាទីដូចគ្នា) គឺធ្វើបានតិចតួចបំផុត។

**តើសភាអាចធ្វើអ្វីបាន ដើម្បីដោះស្រាយបញ្ហានៃការរើសអើងចំពោះស្ត្រី?**

សៀវភៅថ្មីនេះបង្ហាញអំពីវិធីសាស្ត្រដែលសភាអាចប្រើប្រាស់អនុសញ្ញាCEDAW ធ្វើជាក្របខ័ណ្ឌមួយ សម្រាប់ឱ្យមានវឌ្ឍនភាពសមភាពយេនឌ័រ និងសិទ្ធិមនុស្សរបស់ស្ត្រីនិងកុមារី។ សៀវភៅថ្មីនេះផ្តល់ជូនសភា នូវចំណេះដឹងអំពីអនុសញ្ញាCEDAW និងការងាររបស់គណៈកម្មាធិការនេះ។ គណៈកម្មាធិការCEDAW គឺជាក្រុមឃ្លាំមើលដែលសមាជិកជាមន្ត្រីជំនាញៗ មានតួនាទីត្រួតពិនិត្យការអនុវត្ត និងការរីកចម្រើននានា ដែលរាយការណ៍ជូនដោយប្រទេស និងហើយក៏មានតួនាទីឆ្លើយតបចំពោះបណ្តឹងផងដែរ។

សៀវភៅថ្មីនេះផ្តោតលើប្រធានបទជាក់ស្តែងជាច្រើន ពាក់ព័ន្ធអនុសញ្ញាCEDAW ដែលរួមមានផងដែរនូវបរិបទនៃការប្រឈមនានា កើតឡើងដោយសារជម្លោះប្រដាប់អាវុធ អស្ថិរភាពនយោបាយ បម្រែបម្រួលអាកាសធាតុ និងវិបត្តិសុខភាព។ ឧទាហរណ៍ បទឧក្រិដ្ឋនិងការរំលោភសិទ្ធស្ត្រីនិងកុមារី ជាពិសេសអំពើហិង្សាលើស្ត្រី ជារឿយៗកើនឡើងខ្លាំងក្នុងស្ថានភាពជម្លោះ។ អំពើហិង្សានេះ រួមមានការចាប់រំលោភ និងទម្រង់ផ្សេងៗទៀតនៃអំពើហិង្សាលើភេទ ដែលពេលខ្លះត្រូវបានគេប្រើប្រាស់ធ្វើជាស្នៀតមួយ នៃការធ្វើសង្គ្រាម ការជួញដូរមនុស្សដោយខុសច្បាប់ និងរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

សៀវភៅថ្មីនេះ បរិយាយលម្អិតអំពីសកម្មភាពដែលសភាអាចធ្វើបាន ដើម្បីដោះស្រាយអំពើហិង្សា។ សៀវភៅនេះផ្តល់អនុសាសន៍ឱ្យសភា ដាក់គ្រប់សកម្មភាពនៃអំពើហិង្សាលើភេទ ដែលប្រព្រឹត្តិដោយរដ្ឋ (State)និងមិនមែនរដ្ឋ បញ្ចូលទៅក្នុងច្បាប់ជាតិ ដើម្បីឱ្យច្បាស់លាស់ថាទង្វើទាំងអស់នោះត្រូវ បានគេចាត់ទុកជាបទឧក្រិដ្ឋ ត្រូវបានគេស៊ើបអង្កេត ត្រូវបានគេកាត់ទោស និងត្រូវបានគេដាក់ទណ្ឌកម្ម។

សៀវភៅថ្មីនេះ ក៏បានដាក់បញ្ចូលដែរនូវករណីសិក្សាជាច្រើន អំពីវិធីសាស្ត្រដែលសភាប្រទេសនានា បានប្រើប្រាស់ដើម្បីជួយលុបបំបាត់ការរើសអើងចំពោះស្ត្រី។ ឧទាហរណ៍ រដ្ឋសហភាពម៉ិកស៊ិក មានច្បាប់មួយឈ្មោះ ច្បាប់ទូទៅស្តីពីលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានជីវិតដែលគ្មានអំពើហិង្សា (The General Law on Women's Access to Life Free of Violence) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ មួយឆ្នាំក្រោយច្បាប់នេះចូលជាធរមាន គេឃើញមានការអនុម័តនូវថវិកាសាធារណៈសម្រាប់យេនឌ័រ។ ថវិកាមួយនេះ ត្រូវបានប្រើប្រាស់ជាពិសេសដើម្បីផ្តោតលើការទប់ស្កាត់ ដាក់ទណ្ឌកម្ម និងផ្តាច់ឫសគល់អំពើហិង្សាចំពោះស្ត្រី ។

ឧទាហរណ៍ល្អមួយទៀត នៃការអនុវត្តការងារសភាដើម្បីលុបបំបាត់អំពើហិង្សាចំពោះស្ត្រី ក្នុងសៀវភៅ គឺវិធីសាស្ត្រដែលសភាប្រទេសជាច្រើន អាចចូលរួមយ៉ាងសកម្មជាមួយគណៈកម្មាធិការCEDAW។ សាធារណរដ្ឋម៉ាល់ឌីវ ជាលើកទីមួយបានដាក់បញ្ចូលប្រធានគណៈកម្មាធិការសភាផ្នែកសិទ្ធិមនុស្សនិងយេនឌ័រ ចូលជាសមាជិកគណៈប្រតិភូរដ្ឋទទួលបន្ទុកកិច្ចការនេះ ក្នុងឆ្នាំ២០២១ ដែលការធ្វើដូច្នេះ គឺដើម្បីធានាថាសភាក៏មានតួនាទីមួយនៅក្នុងគណៈកម្មាធិការនេះ ហើយសភាអាចតាមដានបានល្អប្រសើរជាងមុននូវរបាយការណ៍ប្រទេសស្តីពីវឌ្ឍនភាពលើការងារនេះ។

**សភា ក្នុងតួនាទីជាភ្នាក់ងារនាំឱ្យមានការផ្លាស់ប្តូរ** (Parliaments as Agents of Change)

សៀវភៅថ្មីនេះ សង្កត់ធ្ងន់អំពីវិធីសាស្ត្រដែលសភាអាចអនុវត្ត ដើម្បីធ្វើខ្លួនជាចលករនៃការផ្លាស់ប្តូរវិជ្ជមានក្នុងការលុបបំបាត់អំពើហិង្សា។ ឧទាហរណ៍ សភាអាចធ្វើជាស្ថាប័នគំរូ បង្ហាញអំពីក្នុងការយល់ដឹង និងការយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាយេនឌ័រ។ សៀវភៅផែនការសកម្មភាពឆ្នាំ២០១២ សម្រាប់ការយល់ដឹងអំពីយេនឌ័រ (The IPU's 2012 Plan of Actions for Gender-Sensitive Parliaments) គឺជាឯកសារគោលនយោបាយគន្លឹះមួយ ដែលបង្ហាញអំពីយុទ្ធសាស្ត្រជាច្រើន ដែលសភាទាំងអស់អាចសម្រាំងយកទៅអនុវត្ត ដោយមិនចាំបាច់គិតថា តើសភានោះមានសមាជិកាច្រើន ឬតិចឡើយ។

**សម្រង់សំដីនៃភាពជាអ្នកដឹកនាំ** (Leadership Quotes)

លោកស្រីCynthia López ប្រធានការិយាល័យសមាជិកាសភា របស់សហភាពអន្តរសភា បានមានប្រសាសន៍ថា៖ "យើងនឹងមិនអាចដោះស្រាយបានឡើយ នូវការប្រឈមនានាពេលបច្ចុប្បន្ន ប្រសិនស្ត្រីដែលមានចំនួនពាក់កណ្តាលនៃប្រជាជនពិភពលោក មិនត្រូវបានគេគិតគូឱ្យបានចូលរួម និងឱ្យបានដឹកនាំពេញទំហឹងនិងស្មើភាព ក្នុងជីវភាពសង្គម នយោបាយ និងសេដ្ឋកិច្ច។ អនុសញ្ញាCEDAW ជួយឱ្យយើងបន្តមានគ្រឹះដ៏រឹងមាំសម្រាប់កសាងបាន នូវពិភពលោកមួយដែលធន់ជាងមុន និងសង្គមមួយដែលមានបរិយាប័ន្នទូលាយជាងមុន។"

លោកស្រីNicole Ameline អ្នកជំនាញរបស់គណៈកម្មាធិការCEDAW និងជាជនបង្គោលរបស់សហភាពអន្តរសភា ធ្លាប់លើកឡើងថា៖ "សមាជិកសភា គឺជាកត្តាជំរុញដ៏សំខាន់នៃការវិវត្តដ៏ត្រឹមត្រូវឆ្ពោះទៅកាន់សមភាពយេនឌ័រ ក្នុងគ្រប់ទិដ្ឋភាពនៃការរស់នៅ។ គណៈកម្មាធិការCEDAW និងសហភាពអន្តរសភា បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាដើម្បី ធានាបានថាស្ថាប័នសភា និងសមាជិកសភាអាចអនុវត្តយ៉ាងពេញលេញ នូវតួនាទីរបស់ខ្លួនក្នុងការនាំមានបម្រែបម្រួល និងក្នុងការលើកកម្ពស់សិទ្ធិស្ត្រីទាំងក្នុងទិដ្ឋភាពច្បាប់ និងអារម្មណ៍របស់ប្រជាពលរដ្ឋ។"

លោកMartin Chungon អគ្គលេខាធិការសហភាពអន្តរសភា បានថ្លែងថា៖"ទោះបីគេឃើញមានវឌ្ឍនភាព និងការអនុម័តស្ទើរពេញពិភពលោកលើអនុសញ្ញាCEDAW ក៏ដោយ ប៉ុន្តែមកទល់នឹងពេលនេះ គេមិនទាន់ឃើញប្រទេសណាមួយ អះអាងថាខ្លួនសម្រេចបានទាំងស្រុងនូវសមភាពយេនឌ័រឡើយ។ ការពិតទៅ បច្ចុប្បន្ននេះវឌ្ឍនភាពនៃសិទ្ធិស្ត្រី និងសមភាពយេនឌ័រ កំពុងប្រឈមនឹងហានិភ័យនៃការរិលថយក្រោយ ដោយសារវិបត្តិជាច្រើន តួយ៉ាងដូចជាវិបត្តិជំងឺឆ្លងកូវីដ-១៩ វិបត្តិបម្រែបម្រួលអាកាសធាតុ និងកំ-ណើននៃអំណាចផ្តាច់ការ។ ឈរលើមូលដ្ឋាននេះ ខ្ញុំសន្និដ្ឋានថា សៀវភៅថ្មីនេះ ចេញផ្សាយចំពេលនៃតម្រូវការ ជាសៀវភៅផ្តល់នូវចលនាការ(momentum)និងជាឯកសាររំលឹកថា ការអនុវត្តអនុសញ្ញាCEDAW គួរតែជាការងារប្រចាំថ្ងៃរបស់យើង"។

សៀវភៅថ្មីត្រូវបានផ្សព្វផ្សាយផ្លូវការក្នុងព្រឹត្តិការណ៍ពិសេសមួយ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣៕

*ព័ត៌មានពីសហភាពអន្តរសភា(IPU) ០២-០៧-២៣- តូនី*

ប្រែសម្រួលពី៖ https://www.ipu.org/news/press-releases/2023-06/new-handbook-mobilizing-parliaments-eliminate-discrimination-against-women

# New handbook: Mobilizing parliaments to eliminate discrimination against women

Twenty years after the first edition, the IPU and the Office of the United Nations High Commissioner for Human Rights (OHCHR) have published a new version of a handbook for parliamentarians on the Convention on the Elimination of All Forms of Discrimination against Women and its Optional Protocol.

**What is the CEDAW Convention?**

More than four decades after its adoption, the United Nations Convention on the Elimination of All Forms of Discrimination against Women (CEDAW) remains an essential tool for achieving gender equality and protecting women's rights in all walks of life – from the family and the classroom to executive boards and political leadership roles.

The new handbook is intended to help parliamentarians translate the Convention into concrete parliamentary action through law-making, budget allocation and parliamentary oversight of government actions. It also encourages parliamentarians to lead the way when it comes to promoting women's rights.

**Discrimination against women**

Gender-based discrimination against women is widespread across the world. IPU data shows that the proportion of women in parliament, despite steady increases over the past few years, has stagnated at around 26%. According to the World Bank, women and girls only hold 77% of the legal rights of men and boys. And the World Economic Forum has calculated that women globally earn around 37% less than men in similar roles and that progress on closing the gender pay gap is extremely slow.

**What can parliaments do?**

The handbook demonstrates how parliaments can use the CEDAW Convention as a framework for advancing gender equality, and the human rights of women and girls. It introduces parliaments to the Convention and the work of the CEDAW Committee, a watchdog body made up of experts that monitors implementation and progress reported by countries as well as responding to complaints.

The handbook focuses on particular themes where the Convention takes on particular relevance, including challenging contexts such as those arising from armed conflicts, political instability, climate change and health crises.

For example, crime and violations of the rights of women and girls normally escalate in conflict situations, especially gender-based violence against women. This violence can include rape and other forms of sexual violence, which can sometimes be used a tactic of war, as well as trafficking, and child and/or forced marriages.

The handbook details what actions parliaments can take to address this violence. It recommends that parliaments include all acts of sexual violence committed by State and non-State perpetrators into national legislation to ensure their criminalization, investigation, prosecution and punishment.

The handbook contains a wealth of case studies of how parliaments are helping eliminate discrimination against women. For example, in Mexico, the General Law on Women's Access to a Life Free of Violence was enacted in 2007, with a gender-sensitive public budget adopted the following year. This specific budget, which focuses on the prevention, sanction and eradication of gender-based violence against women, is outlined in a dedicated annex of the federal public budget.

In other examples of good parliamentary practice, the handbook describes how parliaments can actively engage with the CEDAW Committee. For example, in Maldives, for the first time, the Chair of the Parliamentary Human Rights and Gender Committee was included in the November 2021 State delegation to the Committee to ensure a parliamentary angle and follow-up to the country report on progress.

**Parliaments as agents of change**

The handbook underscores how parliaments can be drivers of change in eliminating discrimination. For example, they can lead by example by becoming gender-sensitive institutions.

The IPU's 2012 Plan of Action for Gender-sensitive Parliaments is a key policy document which presents a broad range of strategies that can be implemented by all parliaments, irrespective of the number of women members.

**Leadership quotes**

*"Today's challenges cannot be overcome if women, who constitute half of the world's population, are excluded from full and equal participation and leadership in economic, political and social life. The Convention therefore continues to serve as a solid foundation for building a more resilient world and more inclusive societies."* Cynthia López Castro, President of the IPU Bureau of Women MPs

*"Parliamentarians are essential drivers of the paradigm shift towards gender parity in all spheres of life. The CEDAW Committee and the IPU have been working closely together to make sure parliaments as institutions and individual MPs can fulfil their transformative role, and advance women's rights both in laws and in the minds."* Nicole Ameline, CEDAW Committee expert and IPU focal point

*"Despite progress and the near universal adoption of the Convention, no country can yet claim to have fully achieved gender equality. Indeed, gains in women's rights and gender equality are at serious risk of being reversed by multiple crises, from the COVID-19 pandemic and climate change, to the rise of authoritarianism. That's why this handbook is timely, as it will provide new momentum and serve as a reminder that the implementation of the Convention should be an everyday task."* Martin Chungong, IPU Secretary General.

The handbook was launched at a special event on Thursday, 22 June 2023: Parliaments and women's rights: Implementing CEDAW, realizing the Universal Declaration of Human Rights for all.